**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :....០១២/២០............**ក.ប** / ស.ជ.ណា.ខ.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការលើកពេលថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២០

យោងច្បាប់ស្តីពីការងារ, ប្រកាសលេខ៣៩៩/១៩ ក.ប/ប្រ.ក.អ.ធ.ក ចុះ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០២០, និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ការឈប់សម្រាក (ចំនួន ៤ថ្ងៃ) ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនៅថ្ងៃទី១៣, ១៤, ១៥ និង១៦ ខែមេសា ឆ្នាំ២០២០ ខាងមុខនេះ ត្រូវបានលើកពេល។

រាជរដ្ឋាភិបាលបានកំណត់ចំនួនថ្ងៃត្រូវសងការឈប់សម្រាកចូលឆ្នាំប្រពៃណីជាតិឆ្នាំនេះចំនួន ៥ថ្ងៃ ជូនបងប្អូនកម្មករនិយោជិតវិញ នៅពេលវេលាសមស្របណាមួយ។ ក្រសួងនឹងធ្វើការជូនដំណឹងជាថ្មីអំពីការឈប់សម្រាកជំនួសថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនេះ បន្ទាប់ពីទទួលបានការកំណត់កាលបរិច្ឆេទជាក់ច្បាស់ណាមួយពីរាជរដ្ឋាភិបាល។

អាស្រ័យហេតុនេះ សូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងបន្តធ្វើការដូចថ្ងៃធម្មតានៅតាមសហគ្រាស គ្រឹះស្ថានរបស់ខ្លួន នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនាពេលខាងមុខនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានសេចក្តីជឿជាក់ថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

*ថ្ងៃ* អង្គារ ១៤កើត *ខែ* ចេត្រ *ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី* ៧ *ខែ* មេសា *ឆ្នាំ២០២០*

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ក្រសួង ស្ថាប័នពាក់ព័ន្ធ
  - "ដើម្បីជូនជ្រាប"
- -មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- -អង្គភាពវិជ្ជាជីវៈគ្រប់លំដាប់ថ្នាក់
  - "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- -ឯកសារ កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៩*